# ព្រះជាម្ចាស់



កាលដើមដំបូងមានតែព្រះជាម្ចាស់ទ្រង់គង់នៅតាំងតែពីដំបូងមករហូតអស់កល្បរៀងទៅ។ គ្មានព្រះណាទៀតដែលកើតមុនទ្រង់ ហើយក្រោយទ្រង់ក៏គ្មានដែរ ទ្រង់ជាវិញ្ញាណ ដែលយើងមិនអាចមើលឃើញឬប៉ះពាល់បានឡើយ។ ទ្រង់មានគ្រប់ទាំងអំណាចចេស្ដា អាចធ្វើអ្វីៗគ្រប់បែបយ៉ាងបាន គ្មានអ្វីដែលទ្រង់ ធ្វើមិនកើតឡើយ។ ទ្រង់គង់នៅគ្រប់ទីកន្លែង ទ្រង់ជ្រាបដឹងពីអ្វីៗសព្វបែបយ៉ាងទាំងអស់ ទ្រង់គ្រប់លក្ខណ៍ក្នុងទ្រង់គ្មានអំពើបាបសោះឡើយ ។ទ្រង់សុចរិត និងស្មោះត្រង់ជាទីបំផុតហើយមិនដែលប្រែប្រួលសោះឡើយ។



ព្រះជាម្ចាស់បានបង្កើតពួកទេវតា ហើយទេវតាទាំងអស់ដែល ព្រះបានបង្កើតមកមានលក្ខណៈល្អឥតខ្ចោះ ។ គេគោរពកោតខ្លាច និងស្តាប់បង្គាប់ព្រះជាម្ចាស់ណាស់ ។ តែក្រោយមកមានមហាទេវតា មួយឈ្មោះ **លូស៊ីហ្វើ** វាបានក្បត់នឹងព្រះជាម្ចាស់ព្រោះវាចង់ធ្វើធំស្មើ នឹងទ្រង់ ។ វាឈប់ស្តាប់បង្គាប់ព្រះ ហើយដើរបំផុសបំផុលទេវតា ឯទៀតអោយឈប់ស្តាប់បង្គាប់ព្រះជាម្ចាស់ដូចវាដែរ ហើយ ស្តាប់បង្គាប់វាវិញ ។ ការដែលវាមិនស្តាប់បង្គាប់ព្រះជាម្ចាស់នាំ អោយវាមានបាប ព្រះជាម្ចាស់ក៏បានទម្លាក់វាពីស្ថានសួគ៌មក ។



អំនួត ភាពអាត្មានិយម ការប្រឆាំងបះបោរ មិនស្តាប់បង្គាប់របស់ទេវតា **លូស៊ីហ្វឺ** ព្រះជាម្ចាស់បានទំលាក់វា និងបក្សពួករបស់វាមកផែនដីដែលត្រូវយើងស្គាល់ថា **សាតាំង** ។



ក្រោយមកទៀតព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃនិងផែនដី ហើយនឹងរបស់សព្វសារពើព្រមទាំងសត្វគ្រប់ប្រភេទ ។ក្នុងនោះព្រះជាម្ចាស់បានបង្កើតមនុស្សអោយមានលក្ខណៈពិសេសដូចជាទ្រង់ ហើយអោយមានអំណាចលើរបស់ទាំងអស់ដែលមានជីវិតនៅលើផែនដីនេះ ។ រួចទ្រង់បានធ្វើសួនច្បារមួយឈ្មោះថា **សួនច្បារអេដែន** ហើយក៏ដាក់មនុស្សដែលទ្រង់បានសូនអោយនៅក្នុងសួនច្បារនោះហើយទ្រង់បានដាក់ឈ្មោះមនុស្សនោះថា **អ័ដាម** ។ ព្រះជាម្ចាស់ទ្រង់ជ្រាបពីសេចក្តីត្រូវការរបស់អ័ដាមដោយឃើញថាគាត់នៅតែម្នាក់ឯង នោះ-មិនស្រួល ហេតុនេះហើយបានជាព្រះជាម្ចាស់ធ្វើអោយគាត់ដេកលក់ ហើយទ្រង់បានដកឆ្អឹងជំនីរបស់គាត់មួយមកជប់អោយក្លាយទៅជាស្រី ហើយអ័រដាមបានដាក់ឈ្មោះនាងថា **អេវ៉ា** ។ អ្នកទាំងពីរបានរស់នៅជាមួយគ្នាដោយសេចក្តីសុខសាន្តហើយមានទំនាក់ទំនងល្អជាមួយនឹងព្រះជាម្ចាស់ ។ ព្រះជាម្ចាស់បានហាមផ្តាច់អ្នកទាំងពីរមិនអោយពួកគេបរិភោគផ្លែឈើដែលនាំអោយស្គាល់ពីរបៀបប្រព្រឹត្តអំពើបាប ។ កាលណាពួកគេបរិភោគផ្លែឈើនោះបណ្តាលអោយស្លាប់ មានន័យថាគេនឹងដាច់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ ។



ថ្ងៃមួយអារក្សសាតាំងដែលជាខ្មាំងសត្រូវនឹងព្រះជាម្ចាស់ វាបានចូលក្នុងសួនច្បារអេដែនក្នុងរូបរាងជាសត្វពស់ហើយល្បួងអេវ៉ាអោយបរិភោគផ្លែឈើដឹងខុសត្រូវ។ ដោយចាញ់សេចក្តីល្បួងអារក្សសាតាំងអ័ដាមនិងអេវ៉ាបានធ្វើខុសនឹងបញ្ញាតិរបស់ព្រះជាម្ចាស់ហើយធ្វើតាមអារក្សវិញ។ ដោយការមិនស្តាប់បង្គាប់ដល់ព្រះជាម្ចាស់ នោះនាំអោយអ្នកទាំងពីរធ្លាក់ទៅក្នុងអំពើបាប។



ព្រះជាម្ចាស់សុចរិតហើយយុត្តិធម៌ ទ្រង់មិនបង្ខំអោយអ្នកណាម្នាក់ដើរតាមព្រះអង្គទេ ហើយមនុស្សម្នាក់ៗមានសិទ្ធិជ្រើសរើសផ្លូវដើរដោយខ្លួនឯង។ ផ្លូវមានពីរ មួយជាផ្លូវនៃការស្តាប់បង្គាប់ព្រះនាំអោយមានជីវិតរស់នៅដ៏សុខសាន្តហើយមានទំនាក់ទំនងល្អជាមួយព្រះ ផ្លូវទីពីរជាផ្លូវមិនស្តាប់បង្គាប់ព្រះដែលនាំអោយជីវិតគេជួបការលំបាកនិងទុក្ខវេទនាគ្រប់បែបយ៉ាងហើយដាច់ទំនាក់ទំនងចេញពីព្រះ។ ចំពោះអ័ដាម និងអេវ៉ា បានជ្រើសរើសយកផ្លូវទីពីរដែលបណ្តាលអោយព្រះជាម្ចាស់ដេញពួកគេចេញពីសួនច្បារអេដែន។



តើមនុស្សប៉ុន្មាននាក់ដែលធ្លាក់ទៅក្នុងអំពើបាប ? ដោយអ័ដាម និងអេវ៉ាដែលជាឪពុកម្តាយដើមរបស់យើងជាអ្នកបំរើនៃអារក្សសាតាំងនោះសូម្បីតែកូនក្មេងដែលមិនទាន់ដឹងក្តីក៏មាននិស្ស័យបាបដែលឆ្លងពីឪពុកម្តាយដើមរហូតដល់កូនចៅជំនាន់ក្រោយៗមក គ្មានអ្នកណាអាចជៀសផុតបានឡើយ ។



ព្រះជាម្ចាស់នៅតែអាណិតស្រលាញ់មនុស្សលោកយ៉ាងខ្លាំង ទ្រង់បានយកនិស្ស័យជាមនុស្សតាមរយៈស្រីក្រមុំព្រហ្មចារីយ៍ម្នាក់ឈ្មោះនាង**ម៉ារា**ដែលជាគូដណ្តឹងរបស់លោក**យ៉ូសែប** ។ទ្រង់បានប្រសូត្រមកមានភាពជាមនុស្ស១០០% ហើយក៏មានភាពជាព្រះ១០០%ដែរ ។ ទ្រង់បានយាងមកដើម្បីបង្ហាញអោយយើងដឹងពីគំរោងការរបស់ព្រះជាម្ចាស់ដើម្បីកុំអោយយើងភ័យខ្លាច ហើយទុកចិត្តដល់ព្រះ ។ទ្រង់មកដកអំពើបាបចេញពីយើង អោយយើងមានសេរីភាព និង បំផ្លាញកិច្ចការរបស់អារក្ស ។ ទ្រង់បានបន្ទាបខ្លួនមកប្រសូត្រនៅក្នុងក្រោលសត្វ ដើម្បីអោយមនុស្សគ្រប់ស្រទាប់វណ្ណៈអាចចូលទៅឯទ្រង់បានគ្រប់ៗគ្នា អោយតែមានចិត្តចង់ចូលទៅឯទ្រង់ ទោះបីជាពួកគេមានវណ្ណៈទាបបំផុតក៏ដោយ ។



នៅពេលព្រះអង្គមានព្រះជន្មបានពាពព្រះវស្សា ទ្រង់សព្វព្រះរាជហឫទ័យសុគតនៅលើឈើឆ្កាង ។ គេបានវាយធ្វើបាបទ្រង់យ៉ាងវេទនាជាទីបំផុត។ គេបានត្មេះតេះដៀលទ្រង់សព្វបែបយ៉ាង តែទ្រង់ស៊ូទ្រាំនឹងទុក្ខលំបាកគ្រប់យ៉ាងព្រមទាំងអត់ធ្មត់ជានិច្ច ។យើងបានដឹងហើយថាទ្រង់គឺជាព្រះ ទ្រង់មិនដែលធ្វើបាបសោះឡើយ ហើយទ្រង់បានជ្រាបដឹងពីហេតុការណ៍គ្រប់បែបយ៉ាងដែលនឹងកើតឡើងជាមុន ។ទ្រង់មានគ្រប់ទាំងរិទ្ធិចេស្តាហេតុអ្វីបានជាទ្រង់មិនរត់គេចឬបំរះអោយរួចពីចំណងនេះទៅ? ហេតុអ្វីបានជាទ្រង់ស៊ូទ្រាំដល់ម្លេះ?

គឺដើម្បីជួយសង្គ្រោះដល់យើងរាល់គ្នាអោយរួចពីបាបដោយសារព្រះលោហិតរបស់ទ្រង់ ។ មានតែព្រះយេស៊ូវតែមួយអង្គគត់ដែលបរិសុទ្ធហើយភាពបរិសុទ្ធរបស់ទ្រង់អាចជួយរំដោះយើងចេញពីបាបបាន ។

យើងរាល់គ្នាគួរតែចងចាំពីព្រឹត្តិការណ៍ដ៏អស្ចារ្យនេះមិនត្រូវបំភ្លេចបានឡើយ ។



ពេលទ្រង់សុគត គេបានយកព្រះសពទ្រង់ ទៅបញ្ចុះក្នុងផ្នូរដោយយកផ្ទាំងថ្មយ៉ាងធំមកបិទផ្ជិត ។ទ្រង់សុគតតែបីថ្ងៃទ្រង់រស់ឡើងវិញ ហើយនេះជាភស្តុតាងបញ្ជាក់ថា ទ្រង់បានឈ្នះលើអំណាចរបស់អារក្សសាតាំង និង សេចក្តីស្លាប់ ។ ការសុគតរបស់ព្រះយេស៊ូវ គឺជាការបើកទ្វារដល់គ្រប់ទាំងមនុស្ស ដើម្បីអោយយើងមានទំនាក់ទំនងល្អជាមួយព្រះជាម្ចាស់ឡើងវិញ ។



បើយើងចង់អោយព្រះយេស៊ូវអត់ទោសបាបអោយយើង ហើយបើយើងចង់ក្លាយទៅជាកូនព្រះ តើយើងត្រូវធ្វើយ៉ាងដូចម្តេច? យើងត្រូវធ្វើដូចជាមនុស្សក្នុងរូបភាពនេះដែរគឺយើងត្រូវចូលមកឯព្រះយេស៊ូវទាំងជាប់ចំណងនៃអំពើបាប។ យើងត្រូវមកលុតជង្គង់នៅចំពោះទ្រង់ សូមអោយទ្រង់អត់ទោសបាបអោយយើងដោយចិត្តក្តុកក្តួល និងនឹកស្តាយពីកំហុសដែលយើងបានប្រព្រឹត្ត យើងមិនត្រូវអៀនខ្មាស់ឡើយ។ យើងត្រូវតែសារភាពបាប ហើយសូមអោយទ្រង់ជួយសំអាតយើងអោយបានស្អាតពីអំពើបាប តាមរយៈព្រះលោហិតរបស់ទ្រង់ ។ យើងត្រូវជឿថាទ្រង់រស់ឡើងវិញ ហើយយើងត្រូវយាងព្រះជាម្ចាស់ មកធ្វើជាម្ចាស់ ជាចៅហ្វាយលើចិត្ត គំនិត និងជីវិតរបស់យើង។



ព្រះយេស៊ូវនឹងផ្ដាច់ចំណងនៃអំពើបាបរបស់យើង ហើយយើងនឹងមានសេរីភាព អារក្សសាតាំងមិនអាចគ្រប់គ្រងលើជីវិតយើងតទៀតឡើយ ។



យើងត្រូវប្រែចិត្តឈប់ដើរតាមផ្លូវរបស់សាតាំងទៀត ។ កាលពីមុនយើងធ្លាប់ប្រព្រឹត្តអំពើបាប ឥឡូវនេះព្រះយេស៊ូវនឹងជួយយើងអោយឈប់ប្រព្រឹត្ត ដូចមុនទៀតហើយ ។ ឈប់ដើរផ្លូវពីរហើយដើរតាមផ្លូវដ៏ល្អតែមួយគត់ គឺដើរតាមព្រះយេស៊ូវគ្រីស្ទ ។ យើងព្យាយាមប្រព្រឹត្តិតែការល្អគឺ សុច្ចរិត យុត្តិធម៌ និងស្មោះត្រង់ជានិច្ច ។ បើយើងធ្វើខុសយើងត្រូវសុំទោសព្រះអង្គភ្លាម នោះទ្រង់នឹងអត់-ទោសបាបអោយយើង ។ ជីវិតរបស់យើង នឹងបានពោរពេញទៅដោយសេចក្តីអំណរ និងសេចក្តីសុខសាន្ត ។



## តើអ្វីខ្លះដែលយើងជាអ្នកជឿព្រះយេស៊ូវត្រូវលះបង់?

-យើងត្រូវឈប់រកគ្រូទាយអោយមើលបាតដៃឬមើលសន្លឹកបៀរ ។ល ។

-យើងត្រូវឈប់ពាក់ខ្សែចង្កេះដែលមានកថាបញ្ចុះដោយមន្តអាគមន៏ ព្រមទាំងឈប់រកគ្រូទាយ ឬ គ្រូមន្តអាគមន៏ទាំងអស់ ។

-យើងឈប់ដុតធូបនៅខ្ទមអ្នកតា ឬ ថ្វាយបង្គំរូបចំលាក់ផ្សេងៗទៀតហើយ ព្រោះរបៀបនេះគឺជាការហៅវិញ្ញាណអាក្រក់អោយវាមកគ្រប់គ្រងក្នុងជីវិតរបស់យើង បើធ្វើដូច្នេះបណ្តាលអោយយើងមានបញ្ហាលើសដើម ។



## តើអ្វីខ្លះដែលយើងជាអ្នកជឿព្រះយេស៊ូវត្រូវធ្វើ?

- យើងត្រូវថ្វាយទ្រព្យសម្បត្តិ ប្ដី កូន ប្រពន្ធ ដល់ព្រះយេស៊ូវគ្រីស្ទ កុំអោយភ័យខ្លាចព្រះអង្គយករបស់យើង ឬធ្វើអោយយើងរងគ្រោះថ្នាក់ឡើយ ។ មានមនុស្សជាច្រើនយល់ច្រលំគេមិនហ៊ានថ្វាយប្ដី កូនឬប្រពន្ធដល់ព្រះជាម្ចាស់ឡើយ ដោយភ័យខ្លាចក្រែងទ្រង់ធ្វើអោយគេវិនាស ឬ ធ្វើអោយគេស្លាប់ នេះជាគំនិតខុសឆ្គងទាំងស្រុង ព្រោះព្រះនៃយើងទ្រង់ល្អ ទ្រង់មិនដែលធ្វើអាក្រក់តបតនឹងយើងឡើយ ។

- យើងត្រូវថ្វាយពេលវេលាដល់ព្រះ គឺត្រូវប្រើពេលវេលា ដើម្បីអានគម្ពីរ អធិដ្ឋាន ប្រកបរៀនសូត្រជាមួយគ្រីស្ទានឯទៀតៗ ទៅសួរសុខទុក្ខស្ត្រីមេម៉ាយ ក្មេងកំព្រា អ្នកកំសត់ ទុរគត ។ល ។

- យើងត្រូវថ្វាយចិត្តដល់ព្រះជាម្ចាស់ គឺយើងមិនជឿព្រះឯទៀត ឬ វិញ្ញាណផ្សេងៗក្រៅពីព្រះយេស៊ូវឡើយ ព្រោះទ្រង់ស្រលាញ់យើងយកព្រះទ័យទុកដាក់នឹងយើង គ្មានអ្នកណាល្អដូចជាទ្រង់ឡើយ ។ និយាយសង្ខេបគឺថា យើងស្រលាញ់ព្រះជាម្ចាស់អោយអស់អំពីចិត្ត ហើយស្រលាញ់អ្នកជិតខាងឱ្យដូចជាស្រលាញ់ខ្លួនឯង ។



ពេលយើងស្លាប់ទៅយើងមិនព្រួយបារម្ភ ឬ ភ័យខ្លាចឡើយ ព្រោះយើងដឹងថាយើងមានកន្លែងមួយដែលព្រះជាម្ចាស់បានរៀបចំសំរាប់យើងជាស្រេច គឺនគរឋានសួគ៌ ។



ប្រសិនជាបងប្អូនព្រមសំរេចចិត្តទទួលជឿព្រះយេស៊ូវគ្រីស្ទជាព្រះសង្គ្រោះរបស់បងប្អូន សូមសម្រួមចិត្តអធិដ្ឋាតាមលំនាំខាងក្រោមៈ

ឱ!ព្រះយេស៊ូវអើយខ្ញុំជឿជាក់ថាទ្រង់គឺជាព្រះដ៏ខ្ពស់បំផុតហើយទ្រង់បានសុគតនៅលើឈើឆ្កាង ដើម្បីអត់ទោសបាបរបស់ខ្ញុំ រួចទ្រង់រស់ពីសុគតឡើងវិញ ។ខ្ញុំដឹងថាខ្ញុំជាមនុស្សដែលមានបាបតាំងពីកំណើតមកខ្ញុំបានធ្វើខុសនឹងបញ្ញាតិទ្រង់ខ្ញុំចង់រួចពីបាបនិងចង់រួចពីអំណាចនៃអារក្សសាតាំងក្នុងជីវិតខ្ញុំ សូមព្រះអង្គអត់ទោសនូវសេចក្តីកំហុសរបស់ខ្ញុំសូមអោយខ្ញុំបានត្រឡប់ទៅជាកូនព្រះ ។ ខ្ញុំព្រមដើរចេញពីអារក្សសាតាំងនិងលែងគោរពចំពោះវាតទៅទៀតហើយ ។ដោយអំណាចព្រះចេស្តារបស់ទ្រង់សូមឱ្យខ្ញុំបានរស់នៅឱ្យបានសមរម្យជាកូនព្រះរហូតដល់អវសាន្តនៃជីវិតខ្ញុំ ។ អរគុណព្រះជាម្ចាស់ដែលទ្រង់បានរៀបចំកន្លែងសំរាប់ខ្ញុំនៅស្ថានសួគ៌ ហើយខ្ញុំនឹងរស់នៅជាមួយទ្រង់រហូតអស់កល្បជានិច្ច ។អាម៉ែន

សៀវភៅនេះលោកអ្នកបានទទួលមកពីៈ

ឈ្មោះព្រះវិហារ.................................................

អាស័យដ្ឋាន .................................................

ទូរស័ព្ទលេខ .................................................

សូមអញ្ជើញមកជួបនឹងខ្ញុំ
ដើម្បីរៀនបន្ថែមទៀតអំពីជីវិតថ្មីដោយសារព្រះយេស៊ូវគ្រីស្ទ ។

រក្សាសិទ្ធិ © ដោយ

អង្គការកុមារកំព្រានៃសេចក្តីសន្យាដំណឹងល្អទាំងបួន

២០១១

"God" — Cambodian
Published by Foursquare Missions Press ©2010